# KHMER- INFLUENZA VACCINATION IN PREGNANCY

# ការចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ នៅពេលមានផ្ទៃពោះ

### ❖ តើរោគគ្រុនផ្តាសាយធំជាអ្វី?

- ជាធម្មតាគេបានស្គាល់ថាជា “ គ្រុនផ្តាសាយ ” រោគគឺជាភាពរាលដាលដ៏ខ្លាំងក្លាណាស់ហើយរោគនេះអាចបណ្តាលដល់ស្លាប់ដោយសារតែមេរោគវីរ៉ុសនៃរោគគ្រុនផ្តាសាយធំដែលបានចម្លងដោយសារការក្អកនឹងកណ្តាស់។
- រោគសញ្ញាខ្លះៗដោយរួម ការគ្រុនក្តៅខ្លាំង ការឈឺបំពង់ក ការក្អក ការឈឺក្បាល ការឈឺសរសៃនឹងឈឺចុកចាប់។

### ❖ តើអ្វីជាការចាក់ថ្នាំបង្ការរោគនេះ?

- ការចាក់ថ្នាំបង្ការរោគផ្សេងៗការពារដល់កុមារនឹងមនុស្សពេញវ័យទាំងឡាយពីការបង្កនូវគ្រោះថ្នាក់ដោយការចម្លងមេរោគផ្សេងៗ។
- ការចាក់ថ្នាំបង្ការរោគបានបង្កើនឡើងនូវភាពការពារដល់ប្រព័ន្ធនៅក្នុងសរីរាង្គកាយដើម្បីប្រយុទ្ធប្រឆាំងនឹងមេរោគចម្លងដ៏សាហាវមួយចំនួនដូចជា៖ រោគគ្រុនផ្តាសាយធំ រលាកថ្លើមបេ៉ ក្អកមាន់ កញ្ជ្រិល ក្រឡាទែននឹងរោគស្អូច។
- ថ្នាំបង្ការរោគ វ៉ាក់ស៊ីនមានមួយចំនួនជាផ្នែកនៃមេរោគវីរ៉ុស ឬមេរោគបាក់តេរីនឹងមានជាបន្ថែមផ្នែកផ្សេងៗទៀតដូចជា៖ ការរក្សាបណ្តុះផ្អាប់ទុកយ៉ូរនឹងសមាសធាតុផ្សេងៗដើម្បីបង្កើននូវភាពស៊ាំ នឹងរោគឲ្យបានកាន់តែប្រសើរឡើង។

### ❖ ហេតុអ្វីស្ត្រីមានផ្ទៃពោះគួរតែចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំនេះ?

- ស្ត្រីមានផ្ទៃពោះភាគច្រើនស្ថិតនៅក្នុងភាពមហានិភ័យដោយឈឺដ៏ធ្ងន់ធ្ងរបណ្តាលមកពីរោគគ្រុនផ្តាសាយធំ បើប្រៀបធៀបទៅនឹងស្ត្រីដែលគ្មានផ្ទៃពោះ។
- ការកើតមានរោគគ្រុនផ្តាសាយធំនៅពេលអ្នកមានផ្ទៃពោះ អាចបណ្តាលឲ្យទៅជាឈឺដ៏ធ្ងន់ធ្ងរដូចជា៖ រោគរលាកសួត នឹងអាចបណ្តាលឲ្យអ្នកមានការរលូតទារកឬបណ្តាលឲ្យទារកអាចកើតមិនគ្រប់ខែផងដែរ។
- ស្ត្រីមានផ្ទៃពោះភាគច្រើនអាចនឹងចូលទៅស្នាក់ព្យាបាលក្នុងមន្ទីរពេទ្យ គឺមានច្រើនជាងស្ត្រីដែលគ្មានផ្ទៃពោះដែលកើតមានរោគគ្រុនផ្តាសាយធំនេះ។
- ការចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ អាចនឹងការពារដល់ម្តាយនឹងទារកពីមហានិភ័យដោយការឈឺដ៏ធ្ងន់ធ្ងរនឹងការចូលទៅស្នាក់ព្យាបាលក្នុងមន្ទីរពេទ្យផងដែរ។

### ❖ តើថ្នាំវ៉ាក់សាំងចាក់បង្ការរោគគ្រុនផ្តាសាយធំនេះប្រកបដោយសុវត្ថិភាពចំពោះស្ត្រីមានផ្ទៃពោះដែរ?

- គឺពិតជាប្រកបដោយសុវត្ថិភាព។ គឺគ្មានភ័ស្តុតាងដោយបញ្ជាក់ពីថ្នាំវ៉ាក់សាំងដែលមិនប្រកបដោយសុវត្ថិភាពដល់ម្តាយនឹងទារកនោះឡើយ។
- គឺពិតជាប្រកបដោយសុវត្ថិភាពនៅក្នុងដំណាក់កាលនៃភាពដែលមានផ្ទៃពោះ។
- គឺគ្មានភ័ស្តុតាំងបញ្ជាក់ពីថ្នាំវ៉ាក់សាំងអាចបណ្តាលឲ្យមានជម្ងឺណាមួយដល់ម្តាយក៏ដូចជាដល់ទារកនោះឡើយ។
- ការចាក់ថ្នាំវ៉ាក់សាំងនេះគឺបានផ្តល់នូវការ ការពារសំរាប់ទារកនៅរយៈពេលក្នុងជីវិត **6** ខែដំបូង មុនពេលទារកអាចនឹងត្រូវបានទទួលការចាក់ថ្នាំបង្ការរោគផ្សេងៗទៀត។

### ❖ តើដោយបែបណា អ្នកនឹងទទួលយកបានពីការចាក់ថ្នាំវ៉ាក់សាំងបង្ការរោគគ្រុនផ្តាសាយធំនេះ?

- ស្ត្រីទាំងឡាយដែលមានផ្ទៃពោះគឺមានសិទ្ធិទទួលយកការចាក់ថ្នាំវ៉ាក់សាំងបង្ការរោគគ្រុនផ្តាសាយនេះឥតគិតថ្លៃឡើយ។
- ការចាក់ថ្នាំបង្ការរោគនេះ គឺបានស្នើសុំឲ្យចាក់នៅដើមខែរដូវគ្រុនផ្តាសាយក្នុងរវាងខែមីនា ប៉ុន្តែក៏អាចទទួលយកការចាក់ថ្នាំបង្ការនេះបានគ្រប់ពេលផងដែរ។
- ការចាក់ថ្នាំវ៉ាក់សាំងនេះ គឺមានផ្តល់ជូននៅមន្ទីរពេទ្យម៉ូណាស់កន្លែងការចាក់ថ្នាំបង្ការរោគ **Monash Immunisation:** ផ្នែកអគារឯកជន **(Private suite I Jessie MacPherson) Level 2:** នៅជាន់ទី **2**។ ទូរស័ព្ទលេខ: **9594 6320** ចាប់ផ្តើការពីម៉ោង **8:30**ព្រឹក ដល់ម៉ោង **4** រសៀល ធ្វើការចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ **(Monday to Friday)**។

**មិនចាំបាច់ធ្វើការណាត់ជួបឡើយ។**

**February 2014**

MonashHealth